# អង្គការសហប្រជាជាតិបដិសេធ«ការសាយភាយតាមប្រព័ន្ធសារព័ត៌មាន» ថាចៅក្រមបានទទួលសេចក្តីណែនាំដើម្បីច្រានចោលករណីចំពោះមុខ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

*នាយកដ្ឋានព័ត៌មានសាធារណៈ ផ្នែកព័ត៌មាននិងផ្សព្វផ្សាយ ញូវយ៉ក*

*ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១១*

*ប្រែសម្រួលដោយ ជា ផល្លា*

សេចក្តីថ្លែងការណ៍ខាងក្រោមនេះ បានចេញផ្សាយនៅថ្ងៃនេះដោយអ្នកនាំពាក្យរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ បាន គីមូន ៖

ការគាំទ្រឯករាជ្យភាពរបស់ដំណើរការក្តី គឺជាមូលដ្ឋានសំខាន់ដែលអង្គការសហប្រជាជាតិគាំទ្របន្តឲ្យមាននៅកម្ពុជា ក៏ដូចនៅកន្លែងផ្សេងៗទៀតដែរ ។ ចៅក្រមនិងព្រះរាជអាជ្ញានៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ត្រូវបានអនុញ្ញាតឲ្យបំពេញតួនាទីដោយសេរីជៀសផុតពីការលូកដៃពីខាងក្រៅពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា អង្គការសហប្រជាជាតិ និងម្ចាស់ជំនួយ និងសង្គមស៊ីវិល ។

សេចក្តីថ្លែងការណ៍នេះបញ្ជាក់ថា អង្គការសហប្រជាជាតិសូមធ្វើការបដិសេធចំពោះការសាយភាយតាមប្រព័ន្ធសារព័ត៌មានដែលថា យើងបានណែនាំសហចៅក្រមស៊ើបអង្កេតរបស់យើងឲ្យបញ្ឈប់ករណី០០៣ ។ សេចក្តីថ្លែងការណ៍នេះសូមបញ្ជាក់ដែរថា អង្គការសហប្រជាជាតិនឹងមិនមានយោបល់ទៅលើបញ្ហាដែលជាកម្មវត្ថុនៃការពិចារណាដោយតុលាការទេ និងការសាយភាយតាមប្រព័ន្ធសារព័ត៌មានចំពោះសកម្មភាពដែលគួរឬមិនគួរធ្វើឡើង ដោយចៅក្រមឬព្រះរាជអាជ្ញា នៅក្នុងករណីណាមួយ ។ តាមបែបបទការងារធម្មតា អង្គការសហប្រជាជាតិ នឹងមិនផ្តល់យោបល់ទៅលើរដ្ឋបាលផ្ទៃក្នុងរបស់អង្គការសហប្រជាជាតិ ឬដំណើរការងាររបស់បុគ្គលិកដែលទាក់ទងនឹង អ.វ.ត.ក នោះទេ។ អង្គការសហប្រជាជាតិនឹងធានាថាសមាសធាតុអន្តរជាតិរបស់ អ.វ.ត.ក រួមទាំងការិយាល័យសហចៅក្រមស៊ើបអង្កេតមានធនធានគ្រប់គ្រាន់ដើម្បីធ្វើការងាររបស់ខ្លួន ។

សេចក្តីប្រកាសដែលធ្វើឡើងដោយសហសហចៅក្រមស៊ើបអង្កេតនៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១នេះ ដែលបានសម្រេចបញ្ចប់សំណុំរឿងស៊ើបអង្កេតរបស់ខ្លួនក្នុងករណី០០៣ គឺជាជំហាន

នៃនីតិវិធីបណ្ដោះអាសន្ន ។ បញ្ហាទាក់ទងនឹងសេចក្ដីសម្រេចនោះនឹងជាកម្មវត្ថុនៃការពិចារណាបន្ថែមដោយសហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា និងអង្គបុរេជំនុំជម្រះ ។ ដំណើរការនីតិវិធីផ្សេងទៀត ដែលអាចផ្ដួចផ្ដើមឡើងដោយសហចៅក្រមស៊ើបអង្កេតនឹងក៏ជាកម្មវត្ថុនៃដំណើរការនិតិវិធីឯករាជ្យ ។

សហចៅក្រមស៊ើបអង្កេតមិនមានកតព្វកិច្ច ដើម្បីផ្ដល់ហេតុផលចំពោះសកម្មភាពរបស់ខ្លួននៅក្នុងដំណាក់កាលស៊ើបអង្កេតក្នុងករណី០០៣នោះទេ ។ ស្របទៅតាមប្រពន្ធ័ច្បាប់“ស៊ីវិលឡ”របស់ព្រះរាជាណាចក្រកម្ពុជានីតិវិធីស៊ើបអង្កេតនៅ អ.វ.ត.ក គឺមិនត្រូវធ្វើឡើងជាសាធារណៈនោះទេហើយគ្រប់អ្នកចូលរួមទាំងអស់ក្នុងនិតិវិធីស៊ើបអង្កេតជាទូទៅត្រូវរក្សាការជាសម្ងាត់ ។

សហចៅក្រមស៊ើបអង្កេតត្រូវចេញជាចុងក្រោយនូវដីកាដំណោះស្រាយក្នុងករណី០០៣ ដែលទាក់ទងទៅនិងជនសង្ស័យនីមួយៗ ថាតើនិងត្រូវបញ្ជូនសាក្សីនោះទៅកាន់តុលាការ ឬច្រានចោលការប្រឆាំងចំពោះជនសង្ស័យនោះ ។ ដីកាដំណោស្រាយត្រូវតែរួមបញ្ចូលមូលហេតុដែលសាធារណជនអាចរកបាន ។ ការប៉ាន់ស្មានទៅលើខ្លឹមសារនៃដីកាដំណោះស្រាយក្នុងដំណាក់កាលនេះមិនបានជួយដល់និតិវិធីឯករាជ្យទេ ។

អង្គការសហប្រជាជាតិកំពុងធ្វើយ៉ាងជិតស្និទ្ធិជាមួយរដ្ឋ ដែលជាម្ចាស់ជំនួយនឹងបន្តគាំទ្រយ៉ាងមុតមាំចំពោះការងាររបស់ អ.វ.ត.ក ។ ថ្មីៗនេះ អ.វ.ត.ក កំពុងតែរៀបចំចាប់ផ្ដើមបើកសវនាការកាត់ក្ដីករណី០០២ នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១១ខាងមុខនេះ ។ ជនជាប់ចោទក្នុងករណី០០២ ដែលជាមេដឹកនាំខ្មែរក្រហមនៅរស់រួមមាន ខៀវ សំផន អតីតប្រធានរដ្ឋ និង នួន ជា “បងធំទីពីរ” បន្ទាប់ពី ប៉ុល ពត ។ សវនាការរបស់មេដឹកនាំទាំងនោះនឹងមានសារៈសំខាន់ជាអន្តរជាតិ និងសាកសមនឹងទទួលការគាំទ្រដ៏ខ្លាំងនិងនៅតែបន្តពីសំណាក់សហគមន៍អន្តរជាតិ ។

- - -

**ដើម្បីជ្រាបជាព័ត៌មានប៉ុណ្ណោះ មិនមែនសម្រាប់កំណត់ត្រាផ្លូវការទេ**